រាជរដ្ឋាភិបាលកម្ពុជា

# គ.ជ.អ.ប NCDD

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ



### ទិដ្ឋភាពទូទៅ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨។ គ.ជ.អ.ប គឺជាយន្តការអន្តរក្រសួងសម្រាប់លើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងប្រទេសកម្ពុជា។

### គោលដៅ

គ.ជ.អ.ប ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលដឹកនាំការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

### បេសកកម្ម

គ.ជ.អ.ប មានបេសកកម្មសំខាន់ៗដូចខាងក្រោម៖

- តាក់តែង និងអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ពិគ្រោះ ពិភាក្សា សម្របសម្រួលជាមួយក្រសួង ស្ថាប័នក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ ធនធាន និងទ្រព្យសម្បត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារ ការទទួលខុសត្រូវ សិទ្ធិ

អំណាច និងគណនេយ្យភាពសម្រាប់ផ្ទេរដល់ក្រុមប្រឹក្សានានានៅថ្នាក់ក្រោមជាតិ។

- សហការជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដើម្បីកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ការពិនិត្យ និងកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក។
- ស្រាវជ្រាវ និងរៀបចំនូវកិច្ចព្រមព្រៀងមួយរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។
- សម្របសម្រួលការធ្វើសុខដុមនីយកម្មការគាំទ្រធនធានរបស់ដៃគូអភិវឌ្ឍន៍នានា។
- ព្រមទាំងអនុវត្តបេសកកម្មចាំបាច់ដទៃទៀត។



## សមាជិកនៃ គ.ជ.អ.ប

| | |
|---|---|
| រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍជនបទ | សមាជិក |
| រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | សមាជិក |
| រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ប្រធានលេខាធិការដ្ឋាននៃ គ.ជ.អ.ប | សមាជិកអចិន្ត្រៃយ៍ |



## របៀបរបបការងារ

- គ.ជ.អ.ប ត្រូវជួបប្រជុំសាមញ្ញរៀងរាល់ពីរ (០២) ខែម្តង និងអាចប្រជុំវិសាមញ្ញតាមការចាំបាច់ តាមការស្នើសុំរបស់ប្រធាន ឬសមាជិកយ៉ាងតិចមួយភាគបី (១/៣)។
- គ.ជ.អ.ប មានអនុគណៈកម្មាធិការជាជំនួយការដូចខាងក្រោម៖
    - អនុគណៈកម្មាធិការមុខងារ និងធនធាន
    - អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ
    - អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
    - អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ

## លេខាធិការដ្ឋាន គ.ជ.អ.ប

គ.ជ.អ.ប មានលេខាធិការដ្ឋានស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ។ លេខាធិការដ្ឋាននេះ បំពេញរាល់កិច្ចការចាំបាច់នានាជាប្រចាំ ដើម្បីធានាឱ្យ គ.ជ.អ.ប បំពេញមុខងាររបស់ខ្លួនបានសមស្រប និងមានប្រសិទ្ធភាព ព្រមទាំងជួយជាជំនួយបច្ចេកទេស និងលេខាធិការដល់អនុគណៈកម្មាធិការនីមួយៗ។ លេខាធិការដ្ឋាន គ.ជ.អ.ប មានអង្គភាពចំណុះចំនួនបួនគឺ ៖

- **អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ៖** សិក្សាស្រាវជ្រាវ និងកំណត់តម្រូវការនៃការរៀបចំ និងតម្រឹមក្របខ័ណ្ឌគតិយុត្តនានាជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានកំណត់ដោយច្បាប់រៀបចំអង្គការ កម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិ។
- **អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន៖** រៀបចំ និងអនុវត្តក្របខ័ណ្ឌការងារត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំ និងការអនុវត្តក្របខ័ណ្ឌគតិយុត្តសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិ។ រៀបចំបង្កើតប្រព័ន្ធប្រមូលចងក្រង និងផ្សព្វផ្សាយព័ត៌មាន និងឯកសារនានាពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- **អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី៖** រៀបចំផែនការអនុវត្តកម្មវិធីជាតិ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប ដើម្បីដាក់ជូន គ.ជ.អ.ប ពិនិត្យ និងអនុម័ត ដោយសហការ និងសម្របសម្រួលជាមួយអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា។
- **អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ៖** សិក្សា និងរៀបចំសៀវភៅណែនាំស្តីពីប្រតិបត្តិការរដ្ឋបាល និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប គ្រប់គ្រង ចាត់ចែង និងផ្តល់សេវាគាំទ្រផ្នែកថវិកា និងរដ្ឋបាលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ចាត់ចែងកិច្ចការរដ្ឋបាលទូទៅដែលបម្រើដល់ការអនុវត្តកម្មវិធីជាតិ ផែនការអនុវត្តកម្មវិធីជាតិ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ។




## កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគឺជារបៀបវារៈការងាររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់រយៈពេល១០ឆ្នាំ (២០១០-២០១៩) ក្នុងដំណើរការកំណែទម្រង់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យដ៏ទូលំទូលាយ និងស៊ីជម្រៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយកំណែទម្រង់នេះក៏មានផលប៉ះពាល់មកលើស្ថាប័ននានានៅថ្នាក់ជាតិផងដែរ។ ម្យ៉ាងទៀត ការរៀបចំអោយមានកម្មវិធីជាតិនេះក៏ជាការបញ្ជាក់អះអាងឡើងវិញនូវការប្ដេជ្ញាចិត្តខាងនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះចក្ខុវិស័យ នយោបាយ និងយុទ្ធសាស្ត្រដែលបានកំណត់រួចហើយក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តច្បាប់រៀបចំអង្គការសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

### គំនូសបំព្រួញ ស្ដីពីកម្មវិធីជាតិ




## ផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (ផអ៣)

ផែនការអនុវត្តន៍រយៈពេលបីឆ្នាំដំបូង (ផអ៣) បង្ហាញពីដំណាក់កាលទី១ (២០១១-២០១៣) នៃកម្មវិធីជាតិរយៈពេល១០ឆ្នាំស្ដីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល។ ផអ៣ ផ្ដោតទៅលើការបង្កើត ការបំពេញមុខងារ អភិបាលកិច្ច និងការត្រួតពិនិត្យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្ដើមជាបឋម គឺនៅថ្នាក់ក្រុង ស្រុក ដើម្បីធានាឱ្យមានកិច្ចសហប្រតិបត្តិការ និងការគាំទ្រប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិរវាង ក្រុង ស្រុក ជាមួយឃុំ សង្កាត់ ក្នុងន័យពង្រឹងថែមទៀតនូវ



សមត្ថភាព និងភាពជាម្ចាស់របស់ឃុំ សង្កាត់ ព្រមទាំងយកចិត្តទុកដាក់ដល់ការពង្រឹងសមត្ថភាពរដ្ឋបាលរាជធានី ខេត្ត។ ជាមួយគ្នានេះដែរ ផអ៣ ក៏ផ្ដោតទៅលើការរៀបចំ តាក់តែងបន្ថែមនូវក្របខ័ណ្ឌគោលនយោបាយនានាផងដែរ។

## អនុកម្មវិធីនានានៃផែនការអនុវត្តរយៈពេលបីឆ្នាំ (ផអ៣)

- អនុកម្មវិធីទី១៖ ការរៀបចំគោលនយោបាយ និងការសម្របសម្រួលកម្មវិធី (អនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប)
- អនុកម្មវិធីទី១ខ៖ ការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាក្នុងការប្រឹក្សាយោបល់ និងរៀបចំគោលនយោបាយ (អនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប)
- អនុកម្មវិធីទី២៖ ការរៀបចំ និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (អនុវត្តដោយក្រសួងមហាផ្ទៃ)
- អនុកម្មវិធីទី៣៖ ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (អនុវត្តដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ)
- អនុកម្មវិធីទី៤៖ ធនធានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ (អនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
- អនុកម្មវិធីទី៥៖ ប្រព័ន្ធកសាងផែនការ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (អនុវត្តដោយក្រសួងផែនការ )
- អនុកម្មវិធីទី៦៖ ការអភិវឌ្ឍសមត្ថភាពសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (អនុវត្តដោយសម្ព័ន្ធភាពជាតិឃុំ សង្កាត់)

## ប្រភពធនធានថវិកា




ដើម្បីឆ្លើយតបទៅនឹងគោលដៅ និងបេសកកម្មខាងលើ គ.ជ.អ.ប មាន៖

- ថវិការបស់ខ្លួនដែលស្ថិតនៅក្នុងខ្ទង់មួយដោយឡែកក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ
- ថវិកាដែលទទួលបានតាមរយៈជំនួយផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងសម្ភារៈពីប្រភពក្នុង និងក្រៅប្រទេស។

## ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន៖ ភាពជាតំណាងសាធារណៈ ស្វ័យភាពរបស់មូលដ្ឋាន ការពិគ្រោះយោបល់និងការចូលរួម ការឆ្លើយតបនិងគណនេយ្យភាព ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន ការលើកស្ទួយសមធម៌ តម្លាភាពនិងសុចរិតភាព និងវិធានការប្រឆាំងអំពើពុករលួយនិងការរំលោភអំណាច។





# អង្គការលេខនៃលេខាធិការដ្ឋាន គ.ជ.អ.ប

**គ.ជ.អ.ប**

- អនុគណៈកម្មាធិការមុខងារ និងធនធាន
- អនុគណៈកម្មាធិការសារពើពន្ធ និងហិរញ្ញវត្ថុ
- អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ

**ប្រធានលេខាធិការដ្ឋាន**

- ក្រុមសវនកម្មផ្ទៃក្នុង
- អនុប្រធាន
- អនុប្រធានប្រតិបត្តិ
- អនុប្រធាន
- ក្រុមជំនួយការ

**អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ**
- ការិយាល័យមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិ
- ការិយាល័យហិរញ្ញវត្ថុ និងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការិ. អភិ.សមត្ថភាពនិងធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការិយាល័យអន្តរវិស័យ និង សហប្រតិបត្តិការ

**អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន**
- ការិយាល័យត្រួតពិនិត្យ និង វាយតម្លៃ
- ការិយាល័យព័ត៌មានវិទ្យា
- ការិយាល័យទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន

**អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី**
- ការិយាល័យអភិវឌ្ឍន៍ និងគ្រប់គ្រងកម្មវិធីជាតិ
- ការិយាល័យគាំទ្រសេវាបច្ចេកទេសទូទៅ
- ការិយាល័យគ្រប់គ្រងគម្រោង

**អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ**
- ការិយាល័យហិរញ្ញវត្ថុ
- ការិយាល័យរដ្ឋបាល និងសារពើភ័ណ្ឌ
- ការិយាល័យលទ្ធកម្ម
- ការិយាល័យគ្រប់គ្រងបុគ្គលិក

ដៃគូអភិវឌ្ឍន៍

**លេខាធិការដ្ឋាន គ.ជ.អ.ប ៖**
ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ
មហាវិថីព្រះនរោត្តម ខណ្ឌចំការមន ក្រុងភ្នំពេញ
ទូរស័ព្ទ: +855 (0)23 362 175
+855 (0)23 720 038
អ៊ីម៉ែល: info@ncdd.gov.kh
គេហទំព័រ: www.ncdd.gov.kh